ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ
# ស្តីពី
# សាលាមធ្យមសិក្សាមូលដ្ឋាន

នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ
ខែឧសភា ឆ្នាំ២០០៨

# មាតិកា


អារម្ភកថា ........................................................................ ២

សេចក្តីផ្តើម........................................................................ ៤

បញ្ញត្តិរបស់សាលាមធ្យមសិក្សាធនធាន........................................ ៦

១.គោលបំណងរបស់សាលាមធ្យមសិក្សាធនធាន.............................. ៧

២.ផលប្រយោជន៍របស់សាលាមធ្យមសិក្សាធនធាន........................... ១០

៣.លក្ខណវិនិច្ឆ័យសាលាមធ្យមសិក្សាធនធាន .............................. ១៤

៤.ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត.......................................................... ១៤

៥.បណ្តាញសាលាមធ្យមសិក្សាធនធាន............................................ ១៥

៦.យុទ្ធសាស្ត្រ.............................................................................. ១៨

# អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡាកសាងគោលនយោបាយសម្រាប់កំណត់និងអភិវឌ្ឍសាលាមធ្យមសិក្សាធនធានទូទាំងប្រទេស។ សាលាមធ្យមសិក្សាធនធាន នឹងក្លាយជាសាលារៀនមួយដែលនាំមុខសាលារៀនមធ្យមសិក្សាដទៃទៀតក្នុងបណ្តាញ។

សាលាមធ្យមសិក្សាដែលកំណត់ជាសាលាមធ្យមសិក្សាធនធាន គឺជាសាលាដែលបានបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវ័ន្ត (អគារសិក្សា សាលប្រជុំ បន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ បណ្តាញទឹក បណ្តាញភ្លើង...) និងបណ្តុះបណ្តាលការប្រើប្រាស់សម្ភាររូបវ័ន្តទាំងនោះ។ សាលាមធ្យមសិក្សាធនធាននឹងចែករំលែកបទពិសោធ ក្នុងការប្រើប្រាស់ធនធានទាំងនោះដល់សាលារៀនក្នុងបណ្តាញ។

យុទ្ធសាស្ត្របណ្តាញសាលាមធ្យមសិក្សាធនធានរួមមានការបណ្តុះវប្បធម៌ធ្វើការងារជាមួយគ្នា ដកពិសោធការងារពីគ្នាទៅវិញទៅមក ការសាមគ្គីសហការគ្នារវាងសាលារៀននានា និងសាលារៀនក្នុងបណ្តាញព្រមទាំងសហគមន៍ទូលំទូលាយ។

សាលាមធ្យមសិក្សាទាំងអស់នឹងស្ថិតក្នុងបណ្តាញនៃសាលាមធ្យមសិក្សាធនធាន ដែលមានកិច្ចសហការគ្នាមួយយ៉ាងជិតស្និទ្ធ។

សាលារៀនមួយចំនួនបានចងក្រងជាបណ្តាញរួចហើយ។ ដូចនេះគប្បីបន្តកសាង និងពង្រីកបណ្តាញនេះបន្ថែមទៀត នៅកម្រិតស្រុក-ខណ្ឌ ឬ ខេត្ត-ក្រុង។

សាលាមធ្យមសិក្សាធនធានជាស្នូលរបស់បណ្តាញដើម្បីជំរុញសហប្រតិបត្តិការរវាងសាលារៀននៅក្នុងបណ្តាញនិងផ្តល់ភាពជាអ្នកដឹកនាំក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។

សាលាមធ្យមសិក្សាធនធាននឹងជំរុញការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ចែករំលែកបទពិសោធក្នុងការបង្រៀន និងរៀន ការងារគ្រប់គ្រង ណែនាំកសាងនិងអនុវត្តផែនការអភិវឌ្ឍសាលារៀន និងអភិវឌ្ឍសមត្ថភាពគ្រូ (តាមរយៈការណែនាំផ្ទាល់ និងការអភិវឌ្ឍវិជ្ជាជីវៈ)។ សាសាមធ្យមសិក្សាធនធាននឹងក្លាយជាសមាសភាគ

ដ៏រឹងមាំមួយនៃយុទ្ធសាស្ត្រ គន្លឹះរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលធ្វើឱ្យសាលាមធ្យមសិក្សាអភិវឌ្ឍ តាមរយៈភាពជាអ្នកដឹកនាំនៃសាលាមធ្យមសិក្សាក្នុងបណ្តាញ។

សាលាមធ្យមសិក្សាធនធានត្រូវបានរំពឹងទុកថា នឹងធ្វើឱ្យគ្រប់សាលាមធ្យមសិក្សាទូទាំងប្រទេសមានការរីកចម្រើន។ ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា សាលាមធ្យមសិក្សាទាំងអស់រួមទាំងសហគមន៍ នឹងទទួលបានផលប្រយោជន៍ជាអតិបរមា បន្ទាប់ពីបានចូលរួមក្នុងបណ្តាញសាលាមធ្យមសិក្សាធនធាន ។

ភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម សិទ្ធី**

# សេចក្ដីផ្ដើម

## ទស្សនវិស័យក្នុងការបង្កើតសាលាមធ្យមសិក្សាធនធាន

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ( ESP) ២០០៦-១០ និងកម្មវិធីគាំទ្រវិស័យអប់រំ (ESSP) ២០០៦-១០

គោលនយោបាយវិស័យអប់រំ បានចែងក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP)២០០៦-១០ និងកម្មវិធីគាំទ្រវិស័យអប់រំ (ESSP) ២០០៦-១០ មានមូលដ្ឋានមកពីយុទ្ធសាស្ត្រចតុកោណ និងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល កម្ពុជា។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំ បានចែងពី ចក្ខុវិស័យ បេសកកម្ម និងគោលនយោបាយសំខាន់ៗរបស់ក្រសួងអប់រំ យុវជន និង កីឡា ដូចតទៅ:

**ចក្ខុវិស័យ**របស់ក្រសួងអប់រំ យុវជន និងកីឡាៈ គឺកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

**បេសកកម្ម**របស់ក្រសួងអប់រំ យុវជន និងកីឡាៈ ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និងកីឡា មានបេសកកម្មដឹកនាំគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍ សេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់និងសកលលោក។

ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ **គោលនយោបាយ**ធំៗចំនួន៣ ដូចខាងក្រោមៈ

- ធានាលទ្ធភាពទទួលសេវាអប់រំប្រកបដោយសមធម៌ សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ
- អភិវឌ្ឍស្ថាប័ន និងកសាងសមត្ថភាពសម្រាប់ធ្វើវិមជ្ឈការការងារអប់រំ។

## សាលាមធ្យមសិក្សាធនធាន

សាលាមធ្យមសិក្សាធនធាននឹងផ្តោតទៅលើ ការធ្វើជាគំរូនៃការងារគ្រប់គ្រង និងអភិបាលកិច្ចចំពោះគ្រប់សាលាមធ្យមសិក្សា ដែលជាបណ្តាញនៅក្នុងខេត្ត ក្រុង និងស្រុក-ខណ្ឌ។

សាលាមធ្យមសិក្សាធនធាននឹងក្លាយជាសាលារៀនដែលឆ្នើម ឈានមុនគេក្នុងការបង្រៀននិងរៀននៅកម្រិត មធ្យមសិក្សាតាមរយៈការសិក្សាស្រាវជ្រាវការបង្កើតគំនិតថ្មីៗក្នុងការបង្រៀននិងរៀន ការផលិតនិងប្រើសម្ភារឧបទេសសាមញ្ញ ដោយប្រើប្រាស់ធនធានមានស្រាប់នៅក្នុងសហគមន៍ និងធ្វើឱ្យសាលាមធ្យមសិក្សាដទៃទៀតអាចអនុវត្តតាមបាន។

សាលាមធ្យមសិក្សាធនធានជាប្រភពធនធាននៃការបង្រៀន និងគ្រប់គ្រងតាមរយៈការរៀបចំធ្វើថ្នាក់និទស្សន៍ និងការបង្រៀនខ្នាតតូច (Micro-teaching)[១] ជាទៀងទាត់ ព្រមទាំងរៀបចំជាវគ្គបំប៉ននានាដើម្បីបង្កើនគុណភាពអភិវឌ្ឍសមត្ថភាពបង្រៀន គ្រប់គ្រង ចំពោះសាលាមធ្យមសិក្សាដែលជាបណ្តាញ និងសាលា មធ្យមសិក្សាដទៃទៀតនៅក្នុង ខេត្ត-ក្រុង និងស្រុក-ខណ្ឌ។

សាលាមធ្យមសិក្សាធនធាននឹងផ្តល់ឱកាសចំពោះសិស្សរៀនពូកែ សិស្សក្រីក្រ សិស្សស្រី និងសិស្សជនជាតិភាគតិច ចូលមកសិក្សា។

---

[1] ការបង្រៀនខ្នាតតូច គឺជាការបង្រៀនដោយដកយកមួយផ្នែកតូចដែលលំបាកនៃមេរៀនមកបង្រៀនសាកល្បង

# បញ្ញត្តិរបស់សាលាមធ្យមសិក្សាធនធាន

សាលាមធ្យមសិក្សាធនធាន គឺជាសាលាមធ្យមសិក្សាមួយនៅស្រុក-ខណ្ឌ ឬខេត្ត-ក្រុង ដែលត្រូវបានជ្រើសរើសឡើង ដើម្បីនាំមុខក្នុងការធ្វើឱ្យសាលារៀនមានការរីកចម្រើនគ្រប់ផ្នែក ជាពិសេសការអនុវត្តកម្មវិធីសិក្សា និងលទ្ធផលសិក្សា។ សាលាមធ្យមសិក្សាធនធាន នឹងក្លាយជាសាលារៀននាំមុខក្នុងបណ្តាញសាលាមធ្យមសិក្សាដែលមានក្នុងមូលដ្ឋាន។

សាលាមធ្យមសិក្សាដែលកំណត់ជាសាលាមធ្យមសិក្សាធនធាន គឺជាសាលាដែលបានបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវ័ន្ត (អគារសិក្សា សាលប្រជុំ បន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ បណ្តាញទឹក បណ្តាញភ្លើង...) និងបណ្តុះបណ្តាលការប្រើប្រាស់សម្ភាររូបវ័ន្តទាំងនោះ។ សាលាមធ្យមសិក្សាធនធាននឹងចែករំលែកបទពិសោធ ក្នុងការប្រើប្រាស់ធនធានទាំងនោះចំពោះសាលារៀនក្នុងបណ្តាញរបស់ខ្លួន។

សាលាមធ្យមសិក្សាធនធាននឹងលើកកម្ពស់វិជ្ជាជីវៈគ្រូ ចែករំលែកបទពិសោធក្នុងការបង្រៀន និងរៀន ការងារគ្រប់គ្រង ណែនាំកសាង និងអនុវត្តផែនការអភិវឌ្ឍសាលារៀន និងអភិវឌ្ឍសមត្ថភាពគ្រូ។

សាសាមធ្យមសិក្សាធនធាននឹងក្លាយជាសមាសភាគដ៏រឹងមាំមួយនៃយុទ្ធសាស្ត្រគន្លឹះរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលធ្វើឱ្យសាលាមធ្យមសិក្សាអភិវឌ្ឍតាមរយៈភាពជាអ្នកដឹកនាំ នៃសាលាមធ្យមសិក្សាក្នុងបណ្តាញ។

# ១. គោលបំណងរបស់សាលាមធ្យមសិក្សាធនធាន

សាលាមធ្យមសិក្សាធនធាននឹងផ្តល់ដល់ក្រសួងអប់រំ យុវជន និងកីឡា ធុរជន និងរាជរដ្ឋាភិបាលនូវឱកាសសម្រាប់ធ្វើការជាមួយគ្នា ដើម្បីបង្កើតហេដ្ឋារចនាសម្ព័ន្ធមួយ ដែលផ្តល់ជាផែនការលម្អិតសម្រាប់ភាពល្អប្រសើរក្នុងការងារអប់រំ ដោយផ្តោតជាពិសេសលើការអនុវត្តគោលនយោបាយកម្មវិធីសិក្សាថ្មី។

សាលាមធ្យមសិក្សាធនធានជានិមិត្តរូបនៃគំរូប្រតិបត្តិនិងកម្មវិធីសកម្មភាពល្អប្រសើរសម្រាប់សាលាមធ្យមសិក្សាដទៃយកទៅអនុវត្ត ដើម្បីសម្រេចបានលទ្ធផលអប់រំខ្ពស់។

សាលាមធ្យមសិក្សាធនធានប្តេជ្ញាចែករំលែកបទពិសោធ ដែលពួកគេមានព្រមទាំងធ្វើការជាមួយនឹងសហគមន៍អប់រំទូលំទូលាយ ដើម្បីបន្តអភិវឌ្ឍការបង្រៀន និងរៀនធ្វើឱ្យសាលារៀនអភិវឌ្ឍជាបន្តបន្ទាប់។

**សាលាមធ្យមសិក្សាធនធានអាចជា:**

- សាលារៀនមានស្រាប់ដែលឆ្លើយតបនឹងលក្ខណវិនិច្ឆ័យគ្រប់គ្រាន់
- សាលារៀនមានស្រាប់តែពុំមានលក្ខណវិនិច្ឆ័យគ្រប់គ្រាន់ ហើយត្រូវបានគាំទ្រដើម្បីអភិវឌ្ឍសាលារៀននោះ ឱ្យបំពេញបានលក្ខណវិនិច្ឆ័យគ្រប់គ្រាន់ (រយៈពេលប៉ាន់ស្មានប្រហែលជា៣ឆ្នាំ) លក្ខណវិនិច្ឆ័យសាលាមធ្យមសិក្សាធនធាននឹងមាននៅក្នុងការណែនាំមួយ។

**សាលាមធ្យមសិក្សាធនធាននឹង ៖**

- ផ្តល់ការដឹកនាំ និងតម្រង់ទិសក្នុងការជួយគាំទ្រដល់ការអនុវត្តកម្មវិធីសិក្សាថ្មីនៅមធ្យមសិក្សាទុតិយភូមិ។
- ប្រើប្រាស់វិធីសាស្រ្តបង្រៀន និងរៀនដែលល្អ ដើម្បីគាំទ្រគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាថ្មី។

- ក្លាយជា(ឬក្នុងអំឡុងពេលជាក់លាក់ណាមួយនឹងក្លាយជា) មជ្ឈមណ្ឌលឧត្តមភាពមួយនៃការបង្រៀននិងរៀន។
- ក្លាយជា(ឬក្នុងអំឡុងពេលជាក់លាក់ណាមួយនឹងក្លាយជា)មជ្ឈមណ្ឌលឧត្តមភាពមួយនៃការប្រតិបត្តិអប់រំ និងគំរូនៃលទ្ធផលសិក្សាដែលអាចផ្សព្វផ្សាយបន្តទៅសាលារៀនដទៃទៀត។
- បង្ហាញថាគ្រប់ផ្នែកទាំងអស់នៃដំណើរការសាលារៀន និងទំនាក់ទំនងសាលារៀន-សហគមន៍ មានការអភិវឌ្ឍទៅមុខ ដោយយកការអភិវឌ្ឍគុណភាពសាលារៀនធ្វើជាមូលដ្ឋាន។
- សរសេរចងក្រងឯកសារ ចែករំលែកឯកសារ និងបង្ហាញបទពិសោធរបស់ពួកគេ ដែលមានក្នុងការផ្តើមគំនិតអនុវត្តកម្មវិធីសិក្សាថ្មី ព្រមទាំងជួយសាលារៀនដទៃទៀតឱ្យចេះតាក់តែង និងអនុវត្តការផ្លាស់ប្តូរក្នុងបរិបទផ្ទាល់ខ្លួនរបស់ពួកគេ។
- ចែករំលែកបទពិសោធនៃការអភិវឌ្ឍធនធានមនុស្ស និងធនធានសម្ភារៈជាមួយសាលារៀនដទៃទៀត។
- ខិតខំឱ្យស្មើនឹងសាលារៀនដែលមានការប្រតិបត្តិនិងលទ្ធផលលេចធ្លោរបស់ប្រទេសមួយចំនួនក្នុងតំបន់។
- ត្រូវបានសាងសង់ថ្មី និង/ឬ ជួសជុលដោយផ្អែកទៅតាមលក្ខខណ្ឌមូលដ្ឋាន និងផ្តល់នូវសម្ភាររូបវន្តពិសេស ដូចជាបណ្ណាល័យ បន្ទប់ពិសោធន៍វិទ្យាសាស្ត្របច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ (ICT )។
- ទទួលមូលនិធិគ្រប់គ្រាន់ពីគ្រប់អ្នកពាក់ព័ន្ធ និង ពីគ្រប់មជ្ឈដ្ឋាន។
- ទទួលមូលនិធិគ្រប់គ្រាន់ ដើម្បីឱ្យសាលារៀនអាចមានបរិក្ខារសំខាន់ៗដូចជាសៀវភៅសិក្សា បរិក្ខារបន្ទប់ពិសោធន៍ កញ្ចប់សម្ភារៈ (Kit) និងកុំព្យូទ័រ

ដែលមានកម្មវិធីផ្នែកទន់ថ្មីៗ និងកម្មវិធីប្រឆាំងនឹងមេរោគដែលមានអាជ្ញាប័ណ្ណ អាចធ្វើឱ្យការប្រើប្រាស់មានប្រសិទ្ធភាព និងធ្វើឱ្យមានបច្ចុប្បន្នភាពនូវកម្មវិធីមួយចំនួន។

- ត្រូវបានផ្តល់អាហារូបករណ៍ដើម្បីជួយសិស្សឱ្យសម្រេចបានការសិក្សាខ្ពស់តាមរយៈអាហារូបករណ៍ ២ប្រភេទគឺ :

១).អាហារូបករណ៍ចំពោះសិស្សពូកែ

២).អាហារូបករណ៍ចំពោះសិស្សក្រីក្រ សិស្សស្រី និងសិស្សជនជាតិភាគតិច។

# ២. ផលប្រយោជន៍របស់សាលាមធ្យមសិក្សាធនធាន

ផលប្រយោជន៍របស់សាលាមធ្យមសិក្សាធនធាន

## ២.១.ចំពោះសិស្ស

- មានឱកាសទទួលយកការបង្រៀន និងរៀនដែលមានគុណភាពខ្ពស់
- មានឱកាសសម្រេចបានលទ្ធផលសិក្សាល្អប្រសើរសម្រាប់សិស្សពូកែភាគច្រើន
- ទទួលបានគោលនយោបាយជួយសិស្សក្រីក្រ និងផ្តល់អាហារូបករណ៍ចំពោះសិស្សពូកែ សិស្សក្រីក្រ សិស្សស្រី និងសិស្សជនជាតិភាគតិច។

## ២.២.ចំពោះបុគ្គលិកអប់រំ

- មាននាយក នាយករងសាលារៀនដឹកនាំប្រកបដោយគុណភាពល្អ និងកោសល្យខ្ពស់ក្នុងមុខវិជ្ជាជីវៈ។
- ទទួលបានរបៀបរៀន និងបន្តរៀនពេញមួយជីវិតជាគំរូសម្រាប់សិស្សយកទៅប្រតិបត្តិតាម។
- ទទួលបានការអភិវឌ្ឍវិជ្ជាជីវៈ និងមានឱកាសបង្កើនបំណិនបង្រៀនតាមមុខវិជ្ជាឯកទេសប្រកបដោយភាពល្អប្រសើរ។
- ទទួលបានការពណ៌នាពីមុខតំណែង (Job Description) (លក្ខណសម្បត្តិបទពិសោធ គុណសម្បត្តិបុគ្គល និងលក្ខណៈដទៃទៀត) ច្បាស់លាស់សម្រាប់គ្រប់តួនាទីបង្រៀនទាំងអស់ ព្រមទាំងតម្រូវការបំពេញការងារដទៃទៀតឱ្យស័ក្តិសមជាសាលារៀនមួយដែលមានបុគ្គលិកអប់រំប្រកបដោយស្តង់ដារខ្ពស់។

- ចូលរួមអភិវឌ្ឍកម្មវិធីវាយតម្លៃការបំពេញការងារមួយ ដោយប្រើប្រាស់អាំងឌីកាទ័រស្វ័យវាយតម្លៃការប្រតិបត្តិលើផ្នែកខ្លះដូចជា ខ្លឹមសារមុខវិជ្ជា និងវិធីសាស្ត្របង្រៀន-រៀន។

## ២.៣.ចំពោះមាតាបិតា និងអាណាព្យាបាលសិស្ស

- មានមោទនភាពដោយសារកូនចៅគាត់ទទួលបានឱកាសអប់រំដ៏ល្អបំផុត មានការគ្រប់គ្រងសាលារៀន និងគ្រប់គ្រងហិរញ្ញវត្ថុមានតម្លាភាព ដោយមានការចូលរួមពីមាតាបិតា អាណាព្យាបាលសិស្ស និងសហគមន៍។
- ទទួលបានព័ត៌មានត្រឡប់ជាប្រចាំពីការអភិវឌ្ឍរបស់កូនចៅគាត់។
- ត្រូវបានគាត់មើលឃើញថាសាលារៀនជាមជ្ឈមណ្ឌលមួយនៃ"សហគមន៍សិក្សា" (ការសិក្សាទៅវិញទៅមក រវាងសិស្ស គ្រូ និងសហគមន៍)។

## ២.៤.ចំពោះសាលារៀន

- ទទួលយក និងគាំទ្រការផ្តួចផ្តើមកម្មវិធីសិក្សាដែលបង្កើតឡើងដោយសិស្ស និងគ្រូបង្រៀន ព្រមទាំងគោលវិធីសិស្សមជ្ឈមណ្ឌល សំដៅទៅរកការសិក្សាពេញមួយជីវិត និងការសិក្សាប្រកបដោយភាពបត់បែន ទន់ភ្លន់រស់រវើក។
- ត្រូវបានទទួលស្គាល់ជាសាលារៀនមួយឈានមុខ (ក្នុងការដឹកនាំអនុវត្តគ្រប់ផ្នែក) ដែលផ្តល់ការបង្រៀន និងរៀន ប្រកបដោយគុណភាពក្នុងស្រុក-ខណ្ឌ ខេត្ត-ក្រុង និងក្នុងប្រទេស។
- ត្រូវបានបំពាក់សម្ភាររូបវន្តប្រកបដោយគុណភាព និងបំប៉នបុគ្គលិកឱ្យមានសមត្ថភាពពេញលេញ ដើម្បីសម្រេចបានវត្ថុបំណងសាលាមធ្យមសិក្សាធនធាន ។

- ក្លាយជា (ក្នុងរយៈពេលជាក់លាក់ណាមួយ) មជ្ឈមណ្ឌលមួយមានលទ្ធផលសិក្សាល្អប្រសើរ និងមានការទទួលស្គាល់ដោយផ្អែកលើគោលការណ៍សាលារៀនមានប្រសិទ្ធភាព។
- កំណត់ចំណុចដៅជាក់លាក់ (ផ្អែកលើលក្ខខណ្ឌមូលដ្ឋាន) ដើម្បីបង្កើនចំនួនសិស្សប្រចាំឆ្នាំ ដែលមានប្រភពមកពីតំបន់ជនបទដាច់ស្រយាល សិស្សក្រីក្រ និង សិស្សជនជាតិភាគតិច។
- កំណត់ចំណុចដៅជាក់លាក់ (ផ្អែកលើលក្ខខណ្ឌមូលដ្ឋាន) ដើម្បីបង្កើនភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិប្រចាំឆ្នាំសិក្សា រួមទាំងសិស្សស្រី សិស្សមកពីតំបន់ជួបការលំបាក តំបន់ដាច់ស្រយាល សិស្សក្រីក្រ និងសិស្សជនជាតិភាគតិច។

## ២.៥.ចំពោះសាលារៀនក្នុងបណ្តាញ

- មានការប្រតិបត្តិបង្រៀននិងរៀនល្អបំផុតដែលបង្ហាញឡើងតាមរយៈការអនុវត្តកម្មវិធីសិក្សាថ្មី។
- អាចរៀនសូត្រយកធ្វើជាគំរូក្នុងការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការរៀន ការដឹកនាំគ្រប់គ្រងសាលារៀន។
- អនុវត្តការងារតាមបែបសហប្រតិបត្តិការមួយ ស្របតាមចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគោលនយោបាយធំទាំង៣ គឺសមធម៌ក្នុងការចូលរៀន គុណភាព និងប្រសិទ្ធភាពសេវាអប់រំ និងការកសាងសមត្ថភាពដើម្បីឈានទៅរបបការងារបែបវិមជ្ឈការ។
- អភិវឌ្ឍសាលារៀនឱ្យក្លាយជាមជ្ឈមណ្ឌលនៃឧត្តមភាពអប់រំ ដោយយកការបង្រៀន និងរៀនជាមូលដ្ឋាន។

- អភិវឌ្ឍសាលារៀនឱ្យក្លាយជាមជ្ឈមណ្ឌលនៃការប្រតិបត្តិគំរូសម្រេចលទ្ធផលខ្ពស់ អាចផ្សព្វផ្សាយបទពិសោធទៅសាលារៀនដទៃទៀត។
- ផ្តល់ឱកាសសម្រាប់ការទទួលស្គាល់ការរៀនពូកែ និងមានគោលនយោបាយគាំទ្រចំពោះសិស្សក្រីក្រ សិស្សស្រី សិស្សមកពីតំបន់ជួបការលំបាក និងសិស្សជនជាតិភាគតិច។

## ៣. លក្ខណវិនិច្ឆ័យសាលាមធ្យមសិក្សាធនធាន

១. សាលារៀនមានទីតាំងក្នុងទីប្រជុំជនខេត្ត-ក្រុង ស្រុក-ខណ្ឌ

២. សាលារៀនមានការគ្រប់គ្រង និងសហការល្អជាមួយសហគមន៍

៣. សាលារៀនមានទីតាំងធំទូលាយ ងាយស្រួលក្នុងការសាងសង់អគារបន្ថែមនៅពេលអនាគត

៤. សាលារៀនមានសុវត្ថិភាព និងសន្តិសុខ ធានាការពារបានរាល់វត្ថុមានតម្លៃក្នុងសាលា

៥. សាលារៀនមានប្រភពថាមពលអគ្គិសនី និងទឹកស្អាតសម្រាប់បម្រើឱ្យបន្ទប់ពិសោធន៍ និងកុំព្យូទ័រ។

## ៤. ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

កម្រិតអប្បបរមា នៃសម្ភាររូបវ័ន្តសម្រាប់សាលាមធ្យមសិក្សាធនធានគឺៈ

- មានការិយាល័យសម្រាប់នាយក នាយករងសាលារៀន និងលេខាធិការ
- មានសាលប្រជុំ សាលគ្រូបង្រៀន បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ ឃ្លាំងសម្រាប់ដាក់សម្ភារៈ និងបន្ទប់សម្រាប់គ្រូរៀបចំមេរៀន
- មានបណ្ណាល័យ
- មានអាហារដ្ឋាន ឬ បន្ទប់រៀបអាហារសម្រន់
- មានបង្គន់អនាម័យ និងបន្ទប់ទឹកនារីគ្រប់គ្រាន់

# ៥. បណ្តាញសាលាមធ្យមសិក្សាធនធាន

## ៥.១.បណ្តាញសាលាមធ្យមសិក្សាធនធាន

យុទ្ធសាស្ត្របណ្តាញសាលាមធ្យមសិក្សាធនធាន រួមមានការបណ្តុះវប្បធម៌ធ្វើការងារជាមួយគ្នា ដកពិសោធការងារពីគ្នាទៅវិញទៅមក ការសាមគ្គីសហការគ្នារវាងសាលារៀននានា និងសាលារៀនក្នុងបណ្តាញព្រមទាំងសហគមន៍ទូលំទូលាយ។

សាលាមធ្យមសិក្សាទាំងអស់នឹងស្ថិតក្នុងបណ្តាញនៃសាលាមធ្យមសិក្សាធនធាន ដែលមានកិច្ចសហការគ្នាមួយយ៉ាងជិតស្និទ្ធ។

សាលាមធ្យមសិក្សាធនធានជាស្នូលរបស់បណ្តាញ។

សាលាមធ្យមសិក្សាធនធាននឹងត្រូវបានផ្តល់អគារ និងសម្ភាររូបវ័ន្តបន្ថែម ដើម្បីជំរុញសហប្រតិបត្តិការរវាងសាលារៀននៅក្នុងបណ្តាញ និងផ្តល់ភាពជាអ្នកដឹកនាំក្នុងផ្នែកអភិវឌ្ឍកម្មវិធីសិក្សា។

## ៥.២.វត្ថុបំណងរបស់បណ្តាញសាលាមធ្យមសិក្សាធនធាន

- បង្កើនឱកាស និងលទ្ធផលអប់រំ ចំពោះសិស្សនៅក្នុងតំបន់របស់បណ្តាញ
- ជំរុញការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន
- លើកកម្ពស់ស្មារតីចែករំលែកបទពិសោធនៃការរៀន និងបង្រៀន
- ពង្រឹងការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំរបស់សាលារៀន
- ណែនាំកសាងផែនការដែលនាំឱ្យសាលារៀនមានការរីកចម្រើន
- អភិវឌ្ឍសមត្ថភាពគ្រូបង្រៀន តាមរយៈការណែនាំផ្ទាល់និងការអភិវឌ្ឍវិជ្ជាជីវៈ
- ប្រែក្លាយសាលាមធ្យមសិក្សាធនធានទៅជាសមាសភាគដ៏រឹងមាំមួយ របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធ្វើឱ្យមានអភិវឌ្ឍនៅមធ្យមសិក្សា។

## ៥.៣.បណ្ដាញសាលាមធ្យមសិក្សាធនធាននឹង៖

- ប្រើធនធានសម្រាប់បណ្ដាញដើម្បីលើកទឹកចិត្តនិងជួយគាំទ្រដល់ការបង្កើតថ្មី
- កសាងទំនុកចិត្តដល់នាយកសាលារៀន និងគ្រូបង្រៀនក្នុងការគាំទ្រដល់ការធ្វើឱ្យមានការផ្លាស់ប្ដូរ និងការបង្កើតថ្មី
- ស្វែងរកភាពជឿនលឿនបំផុតដើម្បីឈានដល់ឧត្តមភាព គាំទ្រយ៉ាងសកម្មដល់ការបង្រៀន ការដឹកនាំក្រុមសិក្សា ការងារពិភាក្សា និងការស្រាវជ្រាវជាគម្រោង
- ធ្វើឱ្យលទ្ធផលការអប់រំរបស់សិស្សកើនឡើង
- កំណត់អាទិភាពគោលដៅបណ្ដាញរបស់ថ្នាក់ខេត្ត-ក្រុង និងថ្នាក់ស្រុក-ខណ្ឌដើរស្របគ្នា
- ប្រើទិន្នន័យរបស់បណ្ដាញ ដើម្បីកំណត់ចំណុចខ្លាំង និងចំណុចខ្វះខាតដែលត្រូវកែលម្អ
- រាយការណ៍ពីប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន
- ប្រើធនធានរបស់បណ្ដាញ ដើម្បីលើកទឹកចិត្តនិងជួយគាំទ្រដល់ការបង្កើតថ្មីតាមរយៈសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈ
- សម្របសម្រួល និងផ្សព្វផ្សាយភាពជោគជ័យរបស់បណ្ដាញ
- កសាងភាពជាដៃគូដ៏ទូលាយជាមួយសហគមន៍ដើម្បជំរុញការសិក្សារបស់សិស្ស និងស្វែងរកមាគ៌ាសម្រាប់ ការសិក្សា និងការបម្រើការងារនៅអនាគត។
- រៀបចំពេលវេលាទៀងទាត់ក្នុងប្រព័ន្ធ ដើម្បីចែករំលែកបទពិសោធល្អៗ
- ទទួលស្គាល់សក្ដានុពលនៃគំនិតផ្ដួចផ្ដើម កម្មវិធីគំរូនានា ដោយជំរុញនិងគាំទ្រដល់ទង្វើទាំងនោះ

- កំណត់កន្លែងដែលមានតម្រូវការដូចគ្នា ដែលអាចក្លាយទៅជាចំណុចដៅរួមនៃការប្រឹងប្រែងសម្រាប់ការរីកចម្រើន
- ជំរុញសាលារៀន ឱ្យសហការគ្នាចែករំលែកគំនិត និងផែនការ
- ប្រើប្រាស់ទិន្នន័យពីបណ្តាញ ដើម្បីកំណត់តម្រូវការអភិវឌ្ឍវិជ្ជាជីវៈនាយកសាលារៀន និងគ្រូបង្រៀន

## ៥.៤.គំនូសតាងបណ្តាញសាលាមធ្យមសិក្សាធនធាន



# ៦. យុទ្ធសាស្ត្រ

## ៦.១.ភារកិច្ចតាមស្ថាប័នអប់រំ

### ៦.១.១.អង្គភាពថ្នាក់កណ្តាល(នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ, នាយកដ្ឋានបណ្តុះបណ្តាល, នាយកដ្ឋានបុគ្គលិក, នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ, អធិការដ្ឋានអប់រំ ... )

- ផ្សព្វផ្សាយគោលនយោបាយសាលាមធ្យមសិក្សាធនធានឱ្យបានទូលំទូលាយតាមគ្រប់រូបភាព
- រៀបចំការណែនាំនិងលិខិតបទដ្ឋាននានាទាក់ទងនឹងសាលាមធ្យមសិក្សាធនធាន
- ទាក់ទងជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីរៀបចំផែនការបំពាក់ហេដ្ឋារចនាសម្ព័ន្ធនិងសម្ភាររូបវ័ន្ត ដល់សាលាមធ្យមសិក្សាធនធាន
- ចុះពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ទាក់ទងនឹងសាលាមធ្យមសិក្សាធនធាន
- រៀបចំប្រកាសទទួលស្គាល់សាលាមធ្យមសិក្សាធនធាន។

### ៦.១.២.មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង

- អភិវឌ្ឍផែនការសម្រាប់រៀបចំបណ្តាញសាលាមធ្យមសិក្សាធនធាន
- រៀបចំការណែនាំដល់សាលាមធ្យមសិក្សាធនធាន និងបណ្តាញ
- ចុះពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយ និងលិខិតបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ទាក់ទងនឹងសាលាមធ្យមសិក្សាធនធាន
- លើកសំណើទៅក្រសួងអប់រំ យុវជន និងកីឡា ( នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ) ដើម្បីសុំប្រកាសទទួលស្គាល់សាលាមធ្យមសិក្សាធនធាន។

៦.១.៣.ការិយាល័យអប់រំយុវជន និងកីឡាស្រុក-ខណ្ឌ

- សម្របសម្រួលការងាររដ្ឋបាលរវាងសាលាមធ្យមសិក្សាធនធាន និងមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង។

៦.១.៤.នាយក នាយករងសាលាមធ្យមសិក្សាធនធាន

- រៀបចំធ្វើផែនការអភិវឌ្ឍនិងអនុវត្តគោលនយោបាយសាលាមធ្យមសិក្សាធនធាន
- រៀបចំការប្រជុំសាលារៀនក្នុងបណ្តាញ
- ផ្សព្វផ្សាយគោលនយោបាយសាលាមធ្យមសិក្សាធនធានដល់អ្នកពាក់ព័ន្ធទាំងអស់
- អភិវឌ្ឍយុទ្ធសាស្ត្រមួយ ដើម្បីកសាងវប្បធម៌នៃការធ្វើការរួមគ្នារវាងបណ្តា សាលារៀន
- ផ្តល់យោបល់ និងចែករំលែកបទពិសោធលើការគ្រប់គ្រង ការរៀន និងបង្រៀន នៅក្នុងបណ្តាញសាលារៀនរបស់ខ្លួន
- ធានាសុវត្ថិភាព សន្តិសុខ ថែទាំបានរាល់ទ្រព្យសម្បត្តិសាលារៀន។

៦.២.កំណត់សាលារៀនដែលជាបណ្តាញរបស់សាលាមធ្យមសិក្សាធនធានទីមួយៗ។

៦.៣.រៀបចំលិខិតបទដ្ឋាន ដើម្បីផ្សព្វផ្សាយដល់សាលារៀនមធ្យមសិក្សាទាំងអស់។

៦.៤.រៀបចំធ្វើសិក្ខាសាលាផ្សព្វផ្សាយដល់គ្រប់សាលាមធ្យមសិក្សាធនធានដែលបាន ជ្រើសរើស ដើម្បីកំណត់ពីតួនាទី ការទទួលខុសត្រូវ និងលទ្ធផលរំពឹងទុក។

៦.៥.គ្រោងសាងសង់អគារធនធាន

- សាងសង់ចាប់ផ្តើមពីខែ ធ្នូ ២០០៧ ដល់ ខែ មិថុនា ២០០៨ចំនួន ៧អគារ ធនធាន នៅ ៧ខេត្ត-ក្រុង

- សាងសង់ចាប់ផ្តើមពីខែឧសភា ២០០៨ ដល់ ខែ ធ្នូ ២០០៨ ចំនួន ៩ អគារធនធាន នៅ៩ ខេត្ត-ក្រុង
- សាងសង់ចាប់ផ្តើមពីខែធ្នូ ២០០៨ ដល់ ខែ មិថុនា ២០០៩ ចំនួន ៨ អគារធនធាននៅ ៨ ខេត្ត-ក្រុង
- តាមរយៈគម្រោងបង្កើនគុណភាពអប់រំ ( EEQP )នឹងមានការកំណត់សាលាមធ្យមសិក្សាធនធានបន្ថែម ចំនួន ៣៦ ទៀត។ ក្រសួងអប់រំ យុវជន និងកីឡា នឹងពិភាក្សាជាមួយគណៈកម្មការនាយកនៃគម្រោងបង្កើនគុណភាពអប់រំ (EEQP) លើកម្មវិធីសាងសង់ និងការរៀបចំថវិកា ។

## ៦.៦.គ្រោងអភិវឌ្ឍសមត្ថភាព

- អភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំនៅមធ្យមសិក្សា
- អភិវឌ្ឍសមត្ថភាពគ្រប់គ្រងរបស់នាយក នាយករងសាលាមធ្យមសិក្សា
- ជំរុញបណ្តាញសាលាមធ្យមសិក្សាធនធានដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ឱ្យទៅជាសាលាមធ្យមសិក្សាធនធាន។

រៀបចំ  និងឧបត្ថម្ភការបោះពុម្ពដោយ

ADB